ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខៈ ២៣៤......សសរ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារដើម្បីចុះត្រួតពិនិត្យលទ្ធផលអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ ជំហានទី ១ ឆ្នាំ ២០១២

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងអនុក្រឹត្យលេខ ១៩៥៦ អនក្រ.តត ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៤២ សជណ.ចក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពី គោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- លិខិតលេខ ១៣៩៧ សជណ.ឧស ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការរៀបចំធ្វើការបែង ចែកសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ព្រមទាំងសម្រាប់ប្រជាពលរដ្ឋទូទៅដោយអនុលោម ទៅតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- សេចក្តីសម្រេចលេខ ០២៧ ដនស/គសសជ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបង្កើតគណៈកម្មការអនុវត្តសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- សេចក្តីសម្រេចលេខ ០៩៥ សសរ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបង្កើតគណៈកម្មការអនុវត្តនីតិវិធីលទ្ធកម្មរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចរចា


អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ

ថ្លៃ និងចុះកិច្ចសន្យាផ្ទាល់ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅចំនួន ១៦ ក្នុងការអភិវឌ្ឍទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារ ដើម្បីចុះត្រួតពិនិត្យលទ្ធផលអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ ជំហានទី ១ ឆ្នាំ ២០១២ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១) ឯកឧត្តមបណ្ឌិត **ឌុច វនទីតូ** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម និងជាអគ្គលេខាធិការ អ.គសសជ | **ប្រធាន** |
| ២) លោក **ឡៅ ទិព្វសីហា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ | **អនុប្រធាន** |
| ៣) លោក **សយ យោសាកា** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញកិច្ច និងជាប្រធានអង្គភាពលទ្ធកម្ម | **សមាជិក** |
| ៤) លោក **តាន់ហ៊ាង ហានីដា** | អនុប្រធាននាយកដ្ឋានសំណង់ | **សមាជិក** |
| ៥) លោក **ហាក់ ហ៊ុន** | ប្រធានការិយាល័យគណនេយ្យ និងជាសមាជិក PEAC | **សមាជិក** |
| ៦) លោក **ស៊ិន សុខុន** | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | **សមាជិក** |
| ៧) លោកស្រី **នួន មន្ថា** | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | **សមាជិក** |
| ៨) តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | **សមាជិក** |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ច ៖

- ចុះពិនិត្យ និងវាយតម្លៃលទ្ធផលការងារស្របតាមកិច្ចសន្យារវាងភាគីអ្នកម្ចាស់ការ និងភាគីអ្នកទទួលការ ក្នុងការអនុវត្តការងារអភិវឌ្ឍន៍ទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ សម្រាប់ឆ្នាំ ២០១២ ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ

ក្រចេះ បាត់ដំបង កំពត ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ព្រះវិហារ បន្ទាយមានជ័យ កំពង់ធំ រតនគីរី មណ្ឌលគីរី កោះកុង និងខេត្តឧត្តរមានជ័យ

- ធ្វើរបាយការណ៍ លើកយោបល់ និងវិធានការដោះស្រាយជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យសម្រេច
- អនុវត្តកិច្ចការផ្សេងៗទៀតដែលឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ប្រគល់ជូន

**ប្រការ ៣.~**

សមាជិកក្រុមការងារដូចមានចែងក្នុងប្រការ ១ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង អាចឲ្យប្រើប្រាស់មន្ត្រីក្រោមឱវាទឲ្យជួយការងារក្នុងករណីចាំបាច់

**ប្រការ ៤.~**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ឯកឧត្តម អស់លោក លោកស្រី ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

**ទេសរដ្ឋមន្ត្រី**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច តេជោ នាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលខេត្តគោលដៅ
- មន្ទីរ ដនសស ខេត្តគោលដៅ
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ